# បទបង្ហាញ
# ស្តីពី
# ការអនុវត្តស្តង់ដាសាលាបឋមសិក្សាគំរូ

**បង្ហាញដោយ**

**លោកបណ្ឌិត កាន់ ពុទ្ធី អនុប្រធាននាយកដ្ឋានបឋមសិក្សា**

*ថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣*

# មាតិកា

១. ស្ថានភាពនៃការអប់រំបឋមសិក្សា

២. លទ្ធផលនៃការសិក្សារបស់សិស្ស

៣. កត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សា

៤. ទស្សនាទាននៃស្តង់ដាសាលារៀនគំរូ

៥. ស្តង់ដាសាលាបឋមសិក្សាគំរូ

៦. យន្តការនៃការអនុវត្ត

៧. បែបបទនិងនីតិវិធីនៃការវាយតម្លៃ

៨. ទិសដៅបន្ត

៩. សេចក្តីសន្និដ្ឋាន

# ១. ស្ថានភាពទូទៅនៃការអប់រំបឋមសិក្សា

ក្នុងឆ្នាំសិក្សា២០២២-២០២៣ ការអប់រំបឋមសិក្សាមានស្ថានភាពដូចតទៅ៖

- សាលាបឋមសិក្សារដ្ឋ ៧ ៣៣៨ និងឯកជន ៧២៩
- សិស្សសាលារដ្ឋ ២ ០៥៧ ៦១២នាក់ និងឯកជន ១៤២ ៤០៩នាក់
- ចំនួនថ្នាក់រៀនរដ្ឋ ៦៣ ២៧១ និងបន្ទប់រៀន ៤៧ ០៣១
- បុគ្គលិកអប់រំរដ្ឋ ៥៧ ៦០៨នាក់ ស្រី ៥៣%
  - ❖ បុគ្គលិកបង្រៀន ៤៥ ១៤៨នាក់
  - ❖ គ្រូបង្រៀនពីរថ្នាក់ពីរពេល ៩ ២៥៥នាក់
  - ❖ គ្រូបង្រៀនថ្នាក់គួប ២ ៦០៦នាក់
  - ❖ គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅ ១២ ៤២៥នា

**រចនាសម្ព័ន្ធ**

ថ្នាក់ជាតិ

↓

មន្ទីរ អ.យ.ក. រាជធានី ខេត្ត

↓

ការិយាល័យ អ.យ.ក. ក្រុង ស្រុក ខណ្ឌ

↓

កម្រងសាលារៀន

↓

សាលារៀន

# ២. លទ្ធផលសិក្សារបស់សិស្ស

- សិស្សមកពីប្រទេសឡាវមានសមត្ថភាពភាគរយកម្រិតទី២ ច្រើនជាងគេ (៥០%) និងទី៦ តែ ២% ប៉ុណ្ណោះ
- សិស្ស វៀតណាម មានកម្រិតសមត្ថភាពទី២ តែ ១% និងទី៦ ចំនួនច្រើនជាងគេ ៨២%។



# ២. លទ្ធផលសិក្សារបស់សិស្ស




## តេស្តវាយតម្លៃថ្នាក់ជាតិ

# ២. លទ្ធផលសិក្សារបស់សិស្ស

តេស្តវាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៦




ប្រភព៖ G6 NLA Datasets 2021

# ២. លទ្ធផលសិក្សារបស់សិស្ស



# កត្តាជះឥទ្ធិពលដល់លទ្ធផលគេស្តរទាបតម្លៃ

- ការចុះឈ្មោះចូលរៀនយឺត
- អត្រាបោះបង់ការសិក្សាខ្ពស់
- អត្រាត្រួតថ្នាក់ខ្ពស់
- គម្លាតលទ្ធផលសិក្សារវាងសិស្សប្រុសនិងសិស្សស្រី
- គម្លាតលទ្ធផលសិក្សារវាងសិស្សនៅទីប្រជុំជន និងជនបទ
- គម្លាតលទ្ធផលសិក្សារវាងសាលារដ្ឋ និងសាលាឯកជន
- គម្លាតលទ្ធផលសិក្សារវាងសិស្សមកពីគ្រួសារអ្នកមាន និងក្រីក្រ



# មូលហេតុនៃលទ្ធផលសិក្សាទាប

- សិស្សមួយចំនួនមករៀនមិនទៀងទាត់ (អវត្តមានច្រើន)
- សិស្សមួយចំនួនមករៀនយឺត
- គ្រូអវត្តមាន និងមកបង្រៀនយឺតមិនទាន់ពេល
- មាតាបិតា អ្នកអាណាព្យាបាលមិនយកចិត្តទុកដាក់លើការសិក្សារបស់កូន
- សាលារៀនហាក់ដូចជាមិនទាន់ផ្តល់ឲ្យសិស្សរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់នៅឡើយដោយសារបញ្ហាបាត់ម៉ោងសិក្សានិងគុណភាពបង្រៀន។

# Years of Schooling are not the same as Learning

Expected years of schooling, unadjusted and adjusted for learning (Human Capital Index 2019)




Note: Cambodia harmonized learning outcome updated to PISA-D average

# គ្រូបង្រៀនជាឆ្អឹងខ្នងនៃវិស័យអប់រំ

- កិត្តិយស គុណភាព ការងាររបស់គ្រូបង្រៀន ជាអាទិភាពរបស់ក្រសួង
- យើងនឹងខិតខំបន្ថែមទៀតដើម្បីលើកកម្ពស់ការបណ្តុះបណ្តាល លក្ខខណ្ឌការងារ និងជីវភាពគ្រូបង្រៀន
- ធ្វើយ៉ាងណាឱ្យសិស្ស មាតាបិតា មហាជនគោរពគ្រូបង្រៀន
- ធ្វើយ៉ាងណាឱ្យគ្រូបង្រៀន **ជាតួឯក**



# ៣. កត្តាជះឥទ្ធិពលដល់ លទ្ធផលសិក្សារបស់សិស្ស



# ៤. ទស្សនាទាននៃសាលារៀនគំរូ

អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងកិច្ចប្រជុំដំបូងគណៈរដ្ឋមន្ត្រី សម្រាប់នីតិកាលទី៧ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ បានលើកឡើងអំពីការលើកកម្ពស់គុណភាពអប់រំ ដោយផ្តោតលើការពង្រឹងគុណភាពសាលារដ្ឋចាប់ពីថ្នាក់មត្តេយ្យសិក្សា ដល់មធ្យមសិក្សា តាមរយៈការពង្រឹងកិច្ចការសំខាន់ៗ រួមមាន៖

ទី១. ការពង្រឹងអភិបាលកិច្ចសាលារៀន

ទី២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាម តម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស

ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួត ពិនិត្យគុណភាពចំណីអាហារនៅតាមសាលា

ទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ក្នុងការ អប់រំស្របតាមពាក្យស្លោកភាពជាដៃគូ រដ្ឋ និងសហគមន៍ដើម្បីការអប់រំ។

# ៤. ទស្សនាទាននៃសាលារៀនគំរូ

- រាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍ដើម្បីដាក់ឱ្យអនុវត្ត **ស្តង់ ដាសាលារៀនគំរូ** និង **ពានរង្វាន់សាលាគំរូ សម្តេចមហាបវរធិបតី** (សជណ ១០០៥ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣)


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ១០០៥ សជណ.អរ

ថ្ងៃ អង្គារ ១១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីសូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីរៀបចំ«ពានរង្វាន់សាលាគំរូ សម្តេចមហាបវរធិបតី» សម្រាប់ការប្រារព្ធ «ទិវាគ្រូបង្រៀន ៥ តុលា»។

**យោង ៖**
- លិខិតលេខ៥៨៩៩ អយក.រប ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា
- លិខិតលេខ០២២ ខន/០២៣ សជណ របស់ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមបណ្ឌិតសភាចារ្យជ្រាបថា រាជរដ្ឋាភិបាលឯកភាពជាគោលការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា អនុវត្ត **"ស្តង់ដាសាលារៀនគំរូ"** និង **"ពានរង្វាន់សាលាគំរូ សម្តេចមហាបវរធិបតី"** ចាប់ពីឆ្នាំសិក្សា២០២៣-២០២៤ តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមបណ្ឌិតសភាចារ្យជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**អ៊ីន ឌីរដ្ឋាភិ**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

# ៤. ទស្សនាទាននៃសាលារៀនគំរូ

- រាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍ ដើម្បីដាក់ឱ្យអនុវត្ត **យុទ្ធនាការសាលារៀនស្អាតគ្មានសំរាម** (សជណ ១០៩៦ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៣)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១០៩៦ សជណ.ឯក

មកដល់ក្រសួង អ.យ.ក
ថ្ងៃ 27 ខែ 10 ឆ្នាំ 2023
លេខ 4596

ថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ:** ករណីសូមគោរពស្នើសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ ដើម្បីដាក់ឱ្យអនុវត្តនូវ «យុទ្ធនាការសាលារៀនស្អាតគ្មានសំរាម» នៅទូទាំងប្រទេស ចាប់ពីឆ្នាំសិក្សា២០២៣-២០២៤ តទៅ។

**យោង** ៖- លិខិតលេខ៦៣៨៤ អយក.រប ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមបណ្ឌិតសភាចារ្យជ្រាបថា រាជរដ្ឋាភិបាលឯកភាពជាគោលការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា ដាក់ឱ្យអនុវត្តនូវ «យុទ្ធនាការសាលារៀនស្អាតគ្មានសំរាម» នៅទូទាំងប្រទេស ចាប់ពីឆ្នាំសិក្សា២០២៣-២០២៤ តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមបណ្ឌិតសភាចារ្យជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**អ៊ីន ធីរជាតិ**

**ចម្លងជូន:**
- គ្រប់ក្រសួងស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

27

## ៤. ទស្សនាទាននៃសាលារៀនគំរូ

ទី១).សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងធ្វើការកែលម្អសាលារៀនស្របតាមស្តង់ដាសាលារៀនគំរូ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធជាពិសេសមាតាបិតា អ្នកអាណាព្យាបាល តាមរយៈការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន,

ទី២).សាលារៀនមានស្វ័យភាពក្នុងការងារផែនការកែលម្អសាលារៀននិងថ្នាក់រៀនព្រមទាំងការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់ គណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀន,

## ៤. ទស្សនាទាននៃសាលារៀនគំរូ

ទី៣).សាលារៀនអនុវត្តតេស្តស្តង់ដាជាប្រចាំ និងប្រើប្រាស់លទ្ធផលនៃតេស្តស្តង់ដា ដើម្បីធ្វើការកែលម្អការបង្រៀននិងរៀន, ការជួយសិស្សរៀនយឺត, និងផ្តល់ព័ត៌មានដល់មាតាបិតាឬអ្នកអាណាព្យាបាល និងសហគមន៍ឱ្យចូលរួមគាំទ្របន្ថែម,

ទី៤).សាលារៀនមានស្វ័យភាពក្នុងអនុវត្តកម្មវិធីសិក្សា និងការរៀបចំកម្មវិធីក្រៅម៉ោងសិក្សា ដោយផ្តោតលើកម្មវិធីអភិវឌ្ឍយុវជន, កម្មវិធីអប់រំច្បាប់ចរាចរ, ការងារស្ម័គ្រចិត្ត, ការងារសហគមន៍ និងការអប់រំសីលធម៌,

## ៤. ទស្សនាទាននៃសាលារៀនគំរូ

ទី៥).សាលារៀនយកចិត្តទុកដាក់លើការអប់រំសុខភាព អនាម័យ បរិស្ថានស្អាត សាលារៀនគ្មានសំរាម និងគិតគូរដល់អាហារូបត្ថម្ភសិស្សានុសិស្ស,

ទី៦).ជំរុញការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការគាំទ្រនិងការអភិវឌ្ឍសាលារៀន។

# ៥. ស្តង់ដាសាលាបឋមសិក្សាគំរូ

សាលាបឋមសិក្សាគំរូ មាន៥ស្តង់ដា៖

- ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស
- ស្តង់ដាទី២៖ ការបង្រៀននិងរៀន
- ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍
- ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន
- ស្តង់ដាទី៥ ៖ គុណនេយ្យភាពរបស់សាលារៀន



## ៥. ស្តង់ដាសាលាបឋមសិក្សាគំរូ

មាន៥ស្តង់ដា ២៦សូចនាករគន្លឹះ និង ៧១សូចនាករលម្អិត

Adobe Acrobat Document

(ឯកសារសូចនាករលម្អិត)

# ៦. យន្តការនៃការអនុវត្ត

· ជ្រើសរើសក្រុមគាំទ្រ/ក្រុមគ្រូបង្វឹក ដែលរួមមាន



មន្ត្រីរបស់នាយកដ្ឋានជំនាញពាក់ព័ន្ធរបស់ក្រសួង មន្ត្រីការិយាល័យជំនាញពាក់ព័ន្ធរបស់មន្ទីរ គ្រូឧទ្ទេសសាលាគរុកោសល្យ មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នាយកសាលាល្អនិងគ្រូបង្រៀនល្អពានរង្វាន់**សម្តេចតេជោសែន** គ្រូបង្រៀនដែលទើបបញ្ចប់ការបណ្តុះបណ្តាលតាមប្រព័ន្ធ១២+៤ និងនាយកសាលា/គ្រូបង្រៀនផ្សេងទៀតដែលមានសមត្ថភាព និងឆន្ទៈចង់ចូលរួមកែទម្រង់សាលារៀន

# ៦. យន្តការនៃការអនុវត្ត



- បែងចែកសាលារៀន នៅក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡាទាំង ២៥រាជធានី ខេត្ត ជា៥តំបន់
- រៀបចំបញ្ជីឈ្មោះអ្នកទទួលខុសត្រូវ ដោយបែងចែក ក្នុង១នាក់ទទួលខុសត្រូវ ៣-៥សាលា
- រៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស) គណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គ.គ.ថ.) និងគណៈកម្មការនានា ដើម្បីគាំទ្រដល់កំណែទម្រង់សាលារៀន

## ៦. យន្តការនៃការអនុវត្ត

- រៀបចំកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ រវាងសាលារៀនជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត មន្ទីរ ជាមួយឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អ.យ.ក.
- រៀបចំកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ រវាងក្រុមក្រុមគាំទ្រ/ក្រុមគ្រូបង្វឹក ជាមួយឯកឧត្តមបណ្ឌិតប្រធាននាយកដ្ឋានបឋមសិក្សា
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្ត ប្រចាំខែ ត្រីមាស និងឆ្នាំ ផ្អែកតាមលទ្ធផលសម្រេចបាន ធៀបនឹងចំណុចដៅនៃសូចនាករដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង។

# ៧. បែបបទនិងនីតិវិធីនៃការវាយតម្លៃ

- ប្រើប្រាស់យន្តការពីលើចុះក្រោម ដោយផ្អែកតាម លទ្ធផលតេស្តវង្វាយតម្លៃថ្នាក់ជាតិ បើសាលាបឋម សិក្សាណា សម្រេចបានលទ្ធផលតេស្តមុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យាចាប់ពី៨០% ឡើងទៅ ដោយក្រសួងនឹងកំណត់ជាសាលាគោលដៅ សម្រាប់ការចុះវាយតម្លៃ



- យន្តការពីក្រោមឡើងលើ សាលាស្នើសុំឱ្យមានការវាយតម្លៃពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ បន្ទាប់មក បញ្ជូនបេក្ខភាពសាលារៀនដែលសម្រេចស្តង់ដា ទៅមន្ទីរ អ.យ.ក. រាជធានី ខេត្ត បន្ទាប់មកមន្ទីរចុះវាយតម្លៃ ហើយបញ្ជូនបេក្ខភាពសាលារៀនជាប់ស្តង់ដា ទៅក្រសួងអប់រំ យុវជន និងកីឡា។

# ៨. ទិសដៅអនុវត្តបន្ត

- បណ្តុះបណ្តាលគ្រូឧទ្ទេសបង្គោល និងក្រុមគាំទ្រ/ក្រុមគ្រូបង្វឹក ដើម្បីបណ្តុះបណ្តាលបន្តដល់អ្នកពាក់ព័ន្ធនៅតាមសាលារៀន
- ប្រជុំណែនាំស្តីពីការអនុវត្តស្តង់ដាសាលារៀនគំរូ ដល់គណៈគ្រប់គ្រងសាលានិងអ្នកពាក់ព័ន្ធ
- រៀបចំអភិវឌ្ឍប្រព័ន្ធ និងប្រមូលទិន្នន័យមូលដ្ឋាន (Baseline) តាមប្រព័ន្ធ Google Form
- ផ្តល់ការអភិវឌ្ឍសមត្ថភាពជាប្រចាំដល់ក្រុមចុះជួយគាំទ្រ/ក្រុមគ្រូបង្វឹក ដើម្បីធានាបាននូវគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល នៃការចុះជួយ តាមរយៈការប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា

# ៨. ទិសដៅអនុវត្តបន្ត

- ក្រុមគាំទ្រ/ក្រុមគ្រូបង្វឹក ចុះផ្ដល់ហ្វឹកហាត់ការដោយផ្ទាល់ដល់គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងអ្នកពាក់ព័ន្ធនៅសាលារៀន
- រៀបចំទស្សនកិច្ចសិក្សា ផ្លាស់ប្ដូរបទពិសោធរវាងសាលារៀនមួយ នឹងសាលារៀនមួយទៀត រវាងសាលារៀនរដ្ឋ និងសាលារៀនឯកជនអន្តរជាតិ រួមទាំងជ្រើសរើសនាយកសាលាគំរូ គ្រូបង្រៀនល្អ ទៅទស្សនកិច្ចសិក្សានៅក្រៅប្រទេស
- រៀបចំការវាយតម្លៃការអនុវត្តស្តង់ដាសាលារៀនគំរូ។

# ៩. សេចក្តីសន្និដ្ឋាន

- ស្តង់ដាសាលាបឋមសិក្សាគំរូ ជាឧបករណ៍សម្រាប់វាយតម្លៃដែលគ្រប់ភាគីពាក់ព័ន្ធ ដូចជារដ្ឋបាលក្រុង ស្រុក ខណ្ឌ, មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត, ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា អាចយកទៅប្រើប្រាស់ក្នុងការវាយតម្លៃ ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍសាលាបឋមសិក្សា នៅកម្ពុជា។

- ក្រសួងសង្ឃឹមថា គ្រប់សាលាបឋមសិក្សាទូទាំងប្រទេស នឹងខិតខំអភិវឌ្ឍខ្លួន ឱ្យស្របតាមស្តង់ដាសាលាបឋមសិក្សាគំរូនេះ ដើម្បីពង្រឹងស័ក្តិសិទ្ធិភាពនៃការអភិវឌ្ឍស្ថាប័ន ប្រកបដោយចីរភាព ឆ្ពោះទៅការលើកកម្ពស់គុណភាពការអប់រំបឋមសិក្សា និងធានាបាននូវប្រសិទ្ធភាពនៃលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរឡើង អនាគតប្រែក្លាយជាពលរដ្ឋល្អ មានគុណសម្បទាពលរដ្ឋសកល សម្រាប់កសាងសង្គមសន្តិភាព នៃជាតិកម្ពុជាជានិរន្តរ៍។

“សាលារៀនគំរូ គ្រូបង្រៀនល្អ សិស្សល្អ ពលរដ្ឋល្អ”

# សំណួរ និងចម្លើយ






## សូមអរគុណ!